**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ១១១៤.....អយក.ប្រក

# ប្រកាស
## ស្តីពី
## តម្លៃសមមូលនៃសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩២ ស្តីពីការបើកសាលារៀនចំណេះទូទៅ ឯកជន
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ប្រកាសលេខ ៩១៨ អយក.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបើកគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន«សាលាអន្តរជាតិ វេសវ៉ែយុ កម្ពុជា»
- យោងតាមពាក្យស្នើសុំរបស់លោក **លី ធីរៈ** ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២

## សម្រេច

**ប្រការ ១.-**

សញ្ញាបត្របញ្ចប់ការសិក្សាថ្នាក់ទី១២ ដែលចេញដោយ «**សាលាអន្តរជាតិ វេសវ៉ែយុ កម្ពុជា**» ត្រូវមានតម្លៃសមមូលនឹងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ និងបំពេញវិជ្ជាដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ប្រការ ២.-**

**-សាលាអន្តរជាតិ ខេសធីយូ កម្ពុជា-** ត្រូវរៀបចំបញ្ជីឈ្មោះសិស្សដែលបានប្រឡងជាប់ជាស្ថាពរក្នុងកម្មវិធីប្រឡងបញ្ចប់ ដោយភ្ជាប់ជាមួយនូវពិន្ទុលទ្ធផលសិក្សារបស់សិស្ស ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យ និងផ្តល់ការឯកភាពជាមុន មុននឹងចេញវិញ្ញាបនបត្របណ្តោះអាសន្ន និង/ឬ បោះពុម្ពសញ្ញាបត្រជូនដល់សិស្សដែលបានប្រឡងជាប់ជាស្ថាពរ។

**ប្រការ ៣.-**

ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិដកហូត ឬ បដិសេធសញ្ញាបត្រថ្នាក់ទី១២ ដែលចេញដោយ **-សាលាអន្តរជាតិ ខេសធីយូ កម្ពុជា-** ក្នុងករណីពិនិត្យឃើញមានភាពមិនត្រឹមត្រូវក្នុងដំណើរការសិក្សា ឬមានភាពមិនត្រឹមត្រូវក្នុងការសម្រេចផ្តល់សញ្ញាបត្រដល់អ្នកសិក្សា។

**ប្រការ ៤.-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបង្កើតគណៈកម្មការដែលមានសមាសភាពមកពីនាយកដ្ឋានធានាគុណភាពអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានជំនាញពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យតាមដានជាប្រចាំលើកម្មវិធីសិក្សា ដំណើរការសិក្សា និងដំណើរការប្រឡងរបស់ **-សាលាអន្តរជាតិ ខេសធីយូ កម្ពុជា-**។ គណៈកម្មការនេះត្រូវរៀបចំស្តង់ដារសម្រាប់វាយតម្លៃលើកម្មវិធីសិក្សា និងដំណើរការរបស់គ្រឹះស្ថានសិក្សាឯកជន ដែលប្រើប្រាស់កម្មវិធីសិក្សាអន្តរជាតិ។ ស្តង់ដារនេះត្រូវរៀបចំទាបបំផុតឱ្យស្មើនឹងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់នាយកដ្ឋានពាក់ព័ន្ធ សាកលវិទ្យាធិការ និងនាយកគ្រប់គ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈ និងឯកជន មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងគ្រឹះស្ថានសិក្សាឯកជន **-សាលាអន្តរជាតិ ខេសធីយូ កម្ពុជា-** ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ [illegible]

ថ្ងៃ សុក្រ ១០រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កន្លែងទទួល**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

-ដើម្បីជូនជ្រាបជាព័ត៌មាន-

- -ដូចប្រការ៦

-ដើម្បីអនុវត្ត-

- -កាលប្បវត្តិ
- -ឯកសារ នា.គុណភាពអប់រំ

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន